ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ____________ កសក

# របាយការណ៍
# ស្ដីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឲ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២២ សរុបមានចំនួន ៣៧ ១៤៤,៨ លានរៀល ក្នុងនោះ ៖

(**ក**) **រដ្ឋបាលកណ្ដាល**៖ បានគ្រោងចំណូលសរុបចំនួន ៣៧ ១៤៣,៤ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១២ ៨៣១,៤ លានរៀល ស្មើនឹង១១៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១(៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ៣២០ លានរៀល ស្មើនឹង១០១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(**ខ**) **មន្ទីររាជធានី ខេត្ត**៖ បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី៣ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ៨ ៧៧៣,៩លានរៀល ស្មើនឹង៥៩,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៩,៥%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(**ក**) **រដ្ឋបាលកណ្ដាល**៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន៨ ៧៧៣,៩លានរៀល ស្មើនឹង៨២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង៩៩,៥%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន ៤ ០៨០,១ លានរៀល ស្មើនឹង៧១,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៣៦,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ៣ ៩២៦,៣ លានរៀល ស្មើនឹង១០៦,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៥,៥ %ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៥៧៤,១ លានរៀល ស្មើនឹង៥១,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៤៦,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤)ផលហិរញ្ញវត្ថុ មានចំនួន ៥៧,១ លានរៀល ជាចំណូលបានមកពីការបង់សំណេស



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ចំណាយប្រាក់បៀវត្ស(៤)ផលផ្សេងៗនិងផលពិសេស មានចំនួន១៣៦,៤លានរៀល គឺជាចំណូលពីលំអៀងនៃការដោះដូរទីតាំងដីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតនៅតំបន់ភ្នំតាម៉ៅក្នុងស្រុកបាទីខេត្តតាកែវ ។

(ខ) **មន្ទីររាជធានី ខេត្ត ៖**

នៅក្នុងត្រីមាសទី៣នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីនៅឡើយ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានល្អស្របទៅតាមកម្មវិធីដែលបានដាក់ចេញ ម៉្យាងទៀតដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពរលូនធៀបនឹងកម្មវិធីដែលបានដាក់ចេញដូចជា៖

(១) ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបានខ្ពស់១៣៦,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាលមកពីចំណូលផលពីព្រៃឈើអនុវត្តបាន៥៨,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៤៨,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន៨២,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៣២,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានល្អបង្គួរធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំឬធៀបនឹងកម្មវិធីដែលបានដាក់ចេញ លទ្ធផលដែលសម្រេចបាននេះគឺដោយសារចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗអនុវត្តបាន៨៤,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៩,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជាការជួលដីទំនេរ និងដីមានអគារអនុវត្តបាន៩៥,៩%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៦២,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វ និងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន១១០,៩%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៦,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបាន៥១,៤%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៤៦,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វ និងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន២២៦,៧៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន៣២១,៦%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០១,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន៦០,៧%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣០,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យតាមសាលក្រមតុលាការអនុវត្តបាន១០២,៤%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០០,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើបទល្មើសជីថ្នាំកសិកម្មអនុវត្តបាន៣៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

## III-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី៤ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន៨ ៩៣០ ៧០០ ០០០រៀល។ កិច្ចការចាំបាច់មួយទៀតដែលក្រសួងត្រូវអនុវត្តគឺបន្តរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈនិងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមក ការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី៣ របស់រដ្ឋបាលកណ្តាលជារួមសម្រេចបានលទ្ធផលល្អប្រសើរធៀបនឹងកម្មវិធីដែលបានដាក់ចេញ ទាំងផ្នែកចំណូលពីសេវាសាធារណៈ ការជួលដីធ្លី និងដីសម្បទានសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី រហូតមកទល់ពេលនេះចំណូលពីការលក់ផលិតផលកសិកម្ម(លក់គោ)នៅភ្នំតាម៉ៅ មិនទាន់បានអនុវត្ត

នៅឡើយ ។ ម្យ៉ាងទៀតចំណូលពីការលក់សម្ភារបរិក្ខារ សម្ភារខូចខាតនិងសម្ភារសិក្សា អនុវត្តបានតិចតួច(២៥,៦% នៃច្បាប់ហិរញ្ញវត្ថុ)។ ចំពោះការជួលទីតាំងដីទំនេររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺមិនបានអនុវត្តបង់ដោយសារកិច្ចសន្យាជួលត្រូវបានបញ្ចប់ យោងតាមលិខិតលេខ៧៨៤ កសរន.កស្ព ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឱ្យបានតាមផែនការឆ្នាំ២០២២ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អនុរដ្ឋលេខាធិការ**

**ឃី កុសល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ______________កសក

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី៣ ឆ្នាំ២០២២
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្តីផ្តើម**:

ឆ្នាំ២០២២ គឺជាឆ្នាំទី៧ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ " ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចិរភាព" ។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២២ សរុបមានចំនួន ២៥៨ ៣២៧ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៦២ ៤២១ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៥៣ ៤២១ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ៩ ០០០ លានរៀល

(ខ) **មន្ទីររាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៥ ៩០៦ លានរៀល

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទអនុវត្តចំណាយ តាមអាណត្តិបើកប្រាក់សរុបចំនួន៧៣ ២៣១,៤ លានរៀលស្មើនឹង៧១,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ក្នុងនោះ រដ្ឋបាលកណ្តាលអនុវត្តបានចំនួន៤៧ ៥៥៨,៩លានរៀល ស្មើនឹង៦៧%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១២៧,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ រីឯមន្ទីររាជធានី ខេត្តអនុវត្តបានចំនួន ២៥ ៦៧២,៥លានរៀល ស្មើនឹង៧៩,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង៩៥,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(ក) **រដ្ឋបាលកណ្តាល**៖

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់


អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា) សម្រេចបានចំនួន៤៧ ៥៥៨,៩លានរៀល ដោយក្នុងនោះ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន៦ ៧០៥,៩ លានរៀល ស្មើនឹង៤៨,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៥,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៦ ២៤៦,៦ លានរៀល ស្មើនឹង៣៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៨៤,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានចំនួន២២ ១៨៥,៧ លានរៀល ស្មើនឹង៧២,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១១០,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៤ ១៥០,៥ លានរៀល ស្មើនឹង៨៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៥,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ពន្ធនិងអាករ(ជំពូក៦៣) អនុវត្តបានចំនួន១១៣,៧ លានរៀល ស្មើនឹង៤៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៣២,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ច)ចំណាយមូលធន (ជំពូក២១) អនុវត្តបានចំនួន៨ ១៥៦,៥ លានរៀល ស្មើនឹង១៣៤,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ។

ម៉្យាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថា ទឹកប្រាក់សរុបចំនួន៤៧ ៥៥៨,៩លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន១២ ៥៨៥,៩លានរៀល ស្មើនឹង៧៣,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២) ចំនួន៤ ០៥១,៥លានរៀល ស្មើនឹង៥៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៣ ១៣៦,៧ លានរៀល ស្មើនឹង៤៩,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៤)គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ(កម្មវិធីទី៤)ចំនួន១ ៥៧២,៧លានរៀលស្មើនឹង៣៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២៦ ២១២លានរៀលស្មើនឹង ៧០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ២៥ ៦៧២,៥លានរៀល គឺអនុវត្តបានខ្ពស់ជាងឆ្នាំ២០២១ក្នុងរយៈពេលដូចគ្នា ប្រមាណជា១៤% ក្នុងនោះចំណាយលើ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន២ ៤៤៤,៧លានរៀល ស្មើនឹង៩៤,២ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១១៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៨ ១៤១,៣លានរៀល ស្មើនឹង៧៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៨,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(គ) បន្ទុកបុគ្គលិក (ជំពូក៦៤ ) អនុវត្តបានចំនួន១៣ ៧០៩,៥ លានរៀល ស្មើនឹង៧៧,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ៩៥,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន១ ៣៥៨ លានរៀល ស្មើនឹង៩១,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០៧,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបានចំនួន ១៩លានរៀល ស្មើនឹង២៤,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣៥,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម៉្យាងទៀត ដោយពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ២៥ ៦៧២,៥លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ | កម្មវិធីត្រីមាសទី៣ | ការអនុវត្តត្រីមាសទី៣ | %អនុ.ត្រឹមត្រី.ទី៣ធៀបច្ប.២០២២ | %ធៀបកម្មវិធីត្រីមាសទី៣ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | 3 820 600 000 | 836 300 000 | 1 242 570 990 | 65.8% | 148.6% |
| បាត់ដំបង | 6 327 800 000 | 1 235 750 000 | 1 131 341 883 | 83.0% | 91.5% |
| កំពង់ចាម | 4 035 000 000 | 932 997 000 | 1 209 884 308 | 88.5% | 129.7% |
| កំពង់ឆ្នាំង | 3 862 500 000 | 1 362 100 000 | 1 410 743 800 | 92.5% | 103.6% |
| កំពង់ស្ពឺ | 4 513 600 000 | 1 374 980 000 | 1 042 830 140 | 82.8% | 75.8% |
| កំពង់ធំ | 5 498 500 000 | 1 578 900 000 | 1 122 723 850 | 73.2% | 71.1% |
| កំពត | 3 933 400 000 | 1 014 859 000 | 889 153 810 | 81.2% | 87.6% |
| កណ្តាល | 6 123 700 000 | 1 842 892 000 | 1 560 079 030 | 77.8% | 84.7% |
| កោះកុង | 2 432 100 000 | 595 000 000 | 1 028 620 978 | 78.1% | 172.9% |
| ក្រចេះ | 3 943 600 000 | 1 047 200 000 | 954 885 567 | 86.5% | 91.2% |
| មណ្ឌលគិរី | 2 774 100 000 | 1 526 000 000 | 1 177 182 200 | 67.6% | 77.1% |
| រាជធានីភ្នំពេញ | 3 843 300 000 | 1 116 521 000 | 841 643 270 | 57.3% | 75.4% |
| ព្រះវិហារ | 2 713 100 000 | 756 004 000 | 652 947 800 | 76.2% | 86.4% |
| ព្រៃវែង | 4 357 400 000 | 896 122 000 | 1 231 405 940 | 88.5% | 137.4% |
| ពោធិ៍សាត់ | 3 822 100 000 | 947 472 000 | 875 331 446 | 81.9% | 92.4% |
| រតនគិរី | 3 147 100 000 | 494 800 000 | 607 618 837 | 90.8% | 122.8% |
| សៀមរាប | 5 700 600 000 | 1 364 789 000 | 1 431 482 650 | 71.4% | 104.9% |
| ព្រះសីហនុ | 2 833 700 000 | 719 355 000 | 775 357 800 | 84.9% | 107.8% |
| ស្ទឹងត្រែង | 3 315 900 000 | 1 170 500 000 | 1 141 077 500 | 89.1% | 97.5% |
| ស្វាយរៀង | 2 998 400 000 | 685 750 000 | 638 472 500 | 87.0% | 93.1% |
| តាកែវ | 5 407 600 000 | 2 274 741 000 | 1 978 000 563 | 88.6% | 87.0% |
| ឧត្តរមានជ័យ | 2 994 800 000 | 543 142 000 | 624 694 750 | 78.0% | 115.0% |
| កែប | 1 646 100 000 | 462 385 000 | 360 370 010 | 49.4% | 77.9% |
| ប៉ៃលិន | 2 161 100 000 | 553 460 000 | 598 151 464 | 90.2% | 108.1% |
| ត្បូងឃ្មុំ | 3 699 900 000 | 1 578 976 000 | 1 145 890 245 | 71.2% | 72.6% |

## III-បញ្ហាប្រឈម

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយចរន្តរបស់រដ្ឋបាលកណ្តាលលើការទិញ (ជំពូក៦០) និងចំណាយសេវាកម្ម(ជំពូក៦១)អនុវត្តបានទាបនៅក្នុងត្រីមាសទី៣ គឺដោយសារអង្គភាពថវិកាមួយចំនួនត្រូវកែសម្រួលផែនការចំណាយពីទូទាត់ត្រង់ ទៅចំណាយតាមនីតិវិធីលទ្ធកម្មវិញ។ ករណីនេះ តម្រូវឱ្យកែឡើងវិញនូវផែនការលទ្ធកម្មចំនួនពីរលើក ម្យ៉ាងទៀតពេលបានធានាចំណាយហើយត្រូវរៀបចំនីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវចំណាយពេលវេលាយូរ។ រីឯការចំណាយបង់ពន្ធរថយន្តក៏អនុវត្តបានទាបនៅឡើយ។ ម្យ៉ាងទៀត ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួន មិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

## IV-ទិសដៅអនុវត្តបន្ត

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី៤ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន៩៣ ៣៣៤ ៦១៥ ០០០រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ ( ការទិញ ) | 9 905 800 000 | 1 742 399 000 |
| ជំពូក ៦១ ( សេវាកម្ម ) | 22 364 200 000 | 7 240 428 000 |
| ជំពូក ៦៤ ( បន្ទុកបុគ្គលិក ) | 32 064 900 000 | 15 308 450 000 |
| ជំពូក៦២( អត្ថប្រយោជន៍សង្គម ) | 60 000 000 | 613 988 000 |
| ជំពូក ៦៥ ( ឧបត្ថម្ភធន ) | 3 893 100 000 | - |
| ជំពូក ៦៣ ( ពន្ធនិងអាករ ) | 89 400 000 | 51 950 000 |
| **សរុប** | **68 377 400 000** | **24 957 215 000** |

## V-សេចក្តីសន្និដ្ឋាន

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី៣ របស់អង្គភាពថវិកានៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន១២៧,២%នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការអនុវត្តចំណាយមូលធន (ជំពូក២១)សម្រេចបានចំនួន៨ ១៥៦,៥លានរៀល ដែលការចំណាយនេះមិនបានគ្រោងក្នុងកម្មវិធីចំណាយប្រចាំត្រីមាសទី៣ឡើយ។ ម៉្យាងទៀតចំណាយជំពូក៦៤ (បន្ទុកបុគ្គលិក) ជំពូក៦៣ (ពន្ធនិងអាករ)និងចំណាយសេវាកម្ម (ជំពូក៦១) អនុវត្តបានខ្ពស់គឺលើសកម្មវិធីដែលបានដាក់ចេញ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការអនុវត្តចំណាយបូកយោងផ្នែកសេវាកម្ម (ជំពូក៦១ )សម្រេចបានទាបនៅឡើយធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានល្អក្នុងកម្រិត ៩៥,៤%នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប និងរាជធានីភ្នំពេញ អនុវត្តចំណាយថវិកាបានទាបធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកា តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អប្រសើរ ទោះបីជាមានការយឺតយ៉ាវខ្លះៗលើការអនុវត្តចំណាយតាមនីតិវិធីលទ្ធកម្ម និងទូទាត់ត្រង់ ប៉ុន្តែចំណាយទាំងនេះនឹងកើនឡើង ពេលទូទាត់បញ្ចប់នៅក្នុងត្រីមាសទី៤ ។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អនុរដ្ឋលេខាធិការ**

**ឃី កុសល**